**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខៈ បព ៧២/២០២៥ កបទ.សអ

**សេចក្តីប្រកាសព័ត៌មាន**

## លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៣ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និង ក្រសួងការបរទេស កំមិនវែល និងអភិវឌ្ឍន៍នៃចក្រភពអង់គ្លេស

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវ ជ្រឹង បុទុមរង្សី រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Dominic Williams ឯកអគ្គរាជទូត នៃចក្រភពអង់គ្លេសប្រចាំកម្ពុជា បានធ្វើជាសហប្រធាននៃកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៣ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស កំមិនវែល និងអភិវឌ្ឍន៍នៃចក្រភពអង់គ្លេសនៅទីក្រុងភ្នំពេញ។

ជាកិច្ចចាប់ផ្តើម លោកជំទាវរដ្ឋលេខាធិការបានចែករំលែកអំពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិ កំណែទម្រង់ស្ថាប័ន និងវិធានការនានាដើម្បីពង្រឹងភាពធន់នៃសេដ្ឋកិច្ច ចំពេលមានបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាជាសកល។ ឯកឧត្តមឯកអគ្គរាជទូតក៏បានផ្តល់ព័ត៌មានថ្មីៗអំពីគោលនយោបាយអាទិភាព បរិយាកាសពាណិជ្ជកម្ម និងវិនិយោគ និងការកំណត់យកវិស័យអាទិភាព ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិរបស់ចក្រភពអង់គ្លេស។

ក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី សហប្រធានទាំងពីរបានសម្តែងការពេញចិត្តចំពោះទំនាក់ទំនងទ្វេភាគីដែលកំពុងរីកចម្រើន និងបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាលើកកម្ពស់កិច្ចសហប្រតិបត្តិការនយោបាយ ការពារជាតិ សេដ្ឋកិច្ច ការអភិវឌ្ឍន៍ និងសន្តិសុខជាដើម។ ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការ រៀបចំកិច្ចពិគ្រោះយោបល់ជាទៀងទាត់ និងជំរុញការផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ដឹកនាំកម្រិតខ្ពស់ ដែលរួមចំណែកពង្រឹងការជឿទុកចិត្តគ្នាទៅវិញទៅមក និងការយល់ដឹងកាន់តែស៊ីជម្រៅរវាងប្រទេសទាំងពីរ។ ចក្រភពអង់គ្លេសក៏បានកត់សម្គាល់ពីវឌ្ឍនភាពរបស់កម្ពុជាក្នុងការលើកកម្ពស់សិទ្ធិមនុស្ស។ ប្រទេសទាំងពីរក៏បានអះអាងសារជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ រួមមានការកសាងសមត្ថភាពដល់មន្ត្រី និងការបន្តរៀបចំទស្សនកិច្ចរបស់នាវាកងទ័ពជើងទឹកអង់គ្លេសមកកាន់កម្ពុជា។

ក្នុងវិស័យសេដ្ឋកិច្ច ភាគីទាំងពីរបានសម្តែងសុទិដ្ឋិនិយមអំពីការពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគ ក្រោមគម្រោងពាណិជ្ជកម្មប្រទេសកំពុងអភិវឌ្ឍន៍ (DCTS) និងបានយល់ឃើញដូចគ្នាថាកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងឯកជនគួរតែត្រូវបានលើកកម្ពស់បន្ថែមទៀត។ ភាគីទាំងពីរទន្ទឹងរង់ចាំការរៀបចំវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នា នៅឆ្នាំក្រោយ ខណៈឯកភាពគ្នាជំរុញការចូលរួមកាន់តែសកម្មក្នុង

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

កិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ ដើម្បីការរីកចម្រើនទៅវិញទៅមក និងលើកកម្ពស់ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន។

លោកជំទាវរដ្ឋលេខាធិការបានសម្តែងអំណរគុណយ៉ាងស្មោះស្ម័គ្ររបស់កម្ពុជាចំពោះការគាំទ្រយ៉ាងសំខាន់របស់ចក្រភពអង់គ្លេស នៅក្នុងវិស័យអប់រំ ការលើកកម្ពស់សិទ្ធិអំណាចស្ត្រី កិច្ចខិតខំប្រឹងប្រែងដោះមីន ការថែទាំសុខភាព ការប្រែប្រួលអាកាសធាតុ និងតំបន់សេដ្ឋកិច្ចពិសេសបៃតងនៅកម្ពុជា។ លោកជំទាវបានបន្ថែមថា ចក្រភពអង់គ្លេសគឺជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់ដែលការគាំទ្របានផ្តល់អត្ថប្រយោជន៍ជាក់ស្តែងដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់កម្ពុជា។ ការគាំទ្រនេះត្រូវបានបង្ហាញតាមរយៈយន្តការនៃកិច្ចសហប្រតិបត្តិការ ដូចជាការផ្លាស់ប្តូរការសិក្សា និងអាហារូបករណ៍ ក៏ដូចជាគំនិតផ្តួចផ្តើមលើកកម្ពស់សមភាពយេនឌ័រ និងការលើកកម្ពស់សិទ្ធិអំណាចស្ត្រី ដែលស្តែងឱ្យឃើញតាមរយៈ កម្មវិធីក្មេងស្រីកាន់តួនាទីជំនួសកាលពី ខែតុលាកន្លងទៅ និងកម្មវិធីពានរង្វាន់ស្ត្រីផ្តើមអាស៊ីអាគ្នេយ៍ ថ្មីៗនេះនៅប្រទេសសិង្ហបុរី។ ជាការឆ្លើយតប ឯកឧត្តមឯកអគ្គរាជទូត បានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញារបស់ចក្រភពអង់គ្លេស ក្នុងការបន្តជួយដល់ប្រទេសកម្ពុជាលើផ្នែកដោះមីន ការអប់រំ ការថែទាំសុខភាព និងបំរែបំរួលអាកាសធាតុផងដែរ។

ភាគីទាំងពីរបានពិភាក្សាអំពីកិច្ចខិតខំប្រឹងប្រែងរួមក្នុងការប្រយុទ្ធប្រឆាំងនឹងបណ្តាញឆបោកតាមអនឡាញ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ស្របតាមអាទិភាពជាតិ និងកាតព្វកិច្ចអន្តរជាតិ។ ថ្នាក់ដឹកនាំទាំងពីរក៏បានសង្កត់ធ្ងន់អំពីតម្រូវការនៃការពង្រឹងកិច្ចសហប្រតិបត្តិការ និងសកម្មភាពរួមគ្នា ដើម្បីការដោះស្រាយបញ្ហាសកលទាំងនេះឱ្យមានប្រសិទ្ធភាព និងបានចែករំលែកការព្រួយបារម្ភអំពីការរីករាលដាលនៃព័ត៌មានក្លែងក្លាយ និងព័ត៌មានមិនពិត។

ភាគីទាំងពីរបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការពហុភាគី រួមមានការគាំទ្រគ្នាទៅវិញទៅមកក្នុងវេទិកាអន្តរជាតិ និងយន្តការដើម្បីជំរុញភាពជាដៃគូសន្ទនាអាស៊ាន-ចក្រភពអង់គ្លេស ក៏ដូចជាការរំលឹកខួបលើកទី ៥ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-ចក្រភពអង់គ្លេសនៅឆ្នាំ ២០២៦។

ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិដែលកំពុងបន្តដែលជាកង្វល់រួម ជាពិសេសជម្លោះប្រដាប់អាវុធជាថ្មីរវាងកម្ពុជា និងថៃ ដោយកត់សម្គាល់ពីតម្រូវការបន្ទាន់ក្នុងការមានបទឈប់បាញ់ ដើម្បីសង្គ្រោះជីវិតជនស៊ីវិល និងទប់ស្កាត់ការបំផ្លិចបំផ្លាញបន្ថែមទៀត។ លោកជំទាវរដ្ឋលេខាធិការ បានរំលឹកឡើងវិញនូវការប្តេជ្ញាចិត្តយ៉ាងស្មោះស្ម័គ្រ និងឥតងាករេរបស់កម្ពុជា ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី និងការអនុវត្តសេចក្តីថ្លែងការណ៍រួម ដែលបានចុះហត្ថលេខានៅទីក្រុងគូឡាឡាំពួ កាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២៥ និងបានអំពាវនាវដល់សហគមន៍អន្តរជាតិ ជំរុញឱ្យប្រទេសថៃបញ្ឈប់ការឈ្លានពានមកលើកម្ពុជា និងគោរពកិច្ចព្រមព្រៀងសន្តិភាព ហើយត្រឡប់ទៅតុចរចាវិញ។

កិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីប្រកបដោយជោគជ័យនេះបង្ហាញពីវឌ្ឍនភាពដ៏មានអត្ថន័យក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការដែលមានផលប្រយោជន៍ទៅវិញទៅមករវាងប្រទេសទាំងពីរ។ ភាគីទាំងពីរនៅតែប្តេជ្ញារក្សាការសន្ទនាជាទៀងទាត់ និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទីបួននៅទីក្រុងឡុងដ៍នៅឆ្នាំក្រោយ។

ថ្ងៃ[illegible] ១០រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR 72/2025 MFA.IC

PRESS RELEASE

## Outcomes of the 3rd Session of Bilateral Political Consultations between the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia and the Foreign, Commonwealth and Development Office of the United Kingdom

On 10 December 2025, **Her Excellency Chring Botumrangsay**, Secretary of State of the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia, and **His Excellency Dominic Williams**, His Majesty's Ambassador of the United Kingdom to Cambodia, successfully co-chaired the third Session of Bilateral Political Consultations between the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia and the Foreign, Commonwealth and Development Office of the United Kingdom in Phnom Penh.

At the outset, Her Excellency the Secretary of State shared the progress made in implementing Cambodia's national development policies, institutional reforms, and measures to strengthen economic resilience amidst global challenges and uncertainty. On the UK's part, His Excellency the Ambassador provided an update on the UK's policy priorities, trade and investment climate, and prioritized sectors of the UK to support national growth.

On the bilateral front, both co-chairs expressed satisfaction with the growing relationship and reaffirmed their commitment to further enhance cooperation in political, defense, economic, development, and security cooperation, among others. They underscored the importance of holding regular consultations and promoting high-level exchanges, which contribute to strengthening mutual trust and deepening understanding between the two countries. The UK acknowledged Cambodia's progress in advancing human rights. The two countries also reaffirmed their commitment to enhancing defense cooperation, including capacity-building for officials, and continued the UK naval ship visits to Cambodia.

In the economic sphere, both sides expressed optimism about strengthening trade and investment relations under the Developing Countries Trading Scheme ( DCTS ) and shared

Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

the view that collaboration between the public and private sectors should be further promoted. They looked forwards to the upcoming Joint Trade and Investment Forum next year while agreeing to foster greater engagement in tourism cooperation for mutual growth and enhanced people-to-people exchange.

Her Excellency Secretary of State, expressed Cambodia's sincere appreciation for the United Kingdom's vital support in education, women's empowerment, demining efforts, healthcare, climate change, and the Green Special Economic Zone in Cambodia. She added that the United Kingdom is a key development partner whose support provides tangible benefits to Cambodia's socio-economic development. This support has been demonstrated through various forms of cooperation, such as academic exchanges and scholarships, as well as initiatives that promote gender equality and women's empowerment – illustrated by the Girl Takeover Program in October and the recent Women of the Future Awards Southeast Asia in Singapore. In response, Ambassador reaffirmed the UK's continued commitment to supporting Cambodia in the areas of demining, education, healthcare and climate change.

Both sides discussed joint efforts to combat online scam networks, human trafficking, and cybercrime in accordance with national priorities and international obligations. They also emphasized the need for strengthened cooperation and collective action to effectively address these global challenges and expressed shared concern over the growing spread of disinformation and misinformation.

They also discussed multilateral cooperation, including mutual support in international platforms, and ways to enhance the ASEAN-UK dialogue partnership as well as the commemoration of 5th Anniversary of ASEAN–UK Dialogue Relations in 2026.

Both sides exchanged views on ongoing regional and international issues of common concern, particularly the renewed armed conflict between Cambodia and Thailand, noting the urgent need to have a ceasefire to save civilian lives and prevent further destruction. Her Excellency Secretary of State reiterated Cambodia's sincere and unwavering commitment to a peaceful settlement of the dispute and to implementation of the Joint Declaration signed in Kuala Lumpur on 26 October 2025 and appealed to the international community to urge Thailand to stop the aggression against Cambodia and respect the peace agreement and go back to the negotiating table.

The successful convening of this Bilateral Consultation marks meaningful progress in advancing mutually beneficial cooperation between the two countries. Both sides remain committed to maintaining regular dialogue and convening the Fourth Bilateral Political Consultation in London next year.

Phnom Penh, 15 December 2025